ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# កំណាព្យ

## សម្រាប់មត្តេយ្យសិក្សា



ឆ្នាំ ២០០៧

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខៈ ៣៦២៤ អយក-សណនន

# សេចក្ដីណែនាំស្ដីពី

# ការប្រើប្រាស់សៀវភៅ "កំណាព្យ"សម្រាប់មត្តេយ្យសិក្សា

**********

ដើម្បីឆ្លើយតបទៅនឹងផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នា២០០៣-២០១៥ ដែលបានកំណត់ថានៅឆ្នាំ ២០១៥ កុមារចំនួន ៧៥%ត្រូវតែបានឆ្លងកាត់កម្មវិធីអប់រំកុមារតូចមុននឹងចូលរៀននៅសាលាបឋមសិក្សា ក្រសួងអប់រំ យុវជន និង កីឡាបានរៀបចំកម្មវិធីគាំពារ និងអភិវឌ្ឍន៍កុមារតូច តាមប្រព័ន្ធសេវាចម្រុះដែលរួមមានសាលា ឬថ្នាក់មត្តេយ្យសិក្សារដ្ឋ ឯកជន សហគមន៍ និងការអប់រំតាមផ្ទះសម្រាប់បង្កលក្ខណៈឱ្យកុមារបានទទួលការអប់រំតាមរយៈសកម្មភាព និងមេរៀនតាមមុខវិជ្ជាសំខាន់ៗ ដូចជាបុរេសំណេរ បុរេគណិត ចិត្តចលភាព ការសង្កេត ចម្រៀង កំណាព្យ រឿងនិទាន គំនូរ សកម្មភាពកសាង និងល្បែងជាដើម ។

សកម្មភាព និងមុខវិជ្ជាទាំងនោះសុទ្ធតែមានការបង្កប់ការអប់រំកុមារ ឱ្យស្គាល់ និងធ្វើអ្វី ដែលជាអំពើល្អត្រឹមត្រូវ ដូចជាការចេះសហការជួយគ្នាទៅវិញទៅមក និងការមិនរើសអើងជាដើម ។

ក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃសកម្មភាពបង្រៀន និងរៀនបន្ថែមទៀត ក្រសួងអប់រំ យុវជន និង កីឡា ដោយមាននាយកដ្ឋានអប់រំកុមារតូច ជាសេនាធិការបានរៀបរៀងសៀវភៅកំណាព្យសម្រាប់មត្តេយ្យសិក្សា និងបានបោះពុម្ពសៀវភៅកំណាព្យនេះ ក្រោមការឧបត្ថម្ភរបស់អង្គការ CYK ។

ដើម្បីឱ្យការប្រើប្រាស់សៀវភៅនេះប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព ក្រសួងអប់រំ យុវជន និង កីឡា សូមធ្វើ ការណែនាំដូចតទៅ :

១-សៀវភៅ"**កំណាព្យ**"សម្រាប់មត្តេយ្យសិក្សាត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់នៅតាមសាលា ឬថ្នាក់មត្តេយ្យសិក្សារដ្ឋ ឯកជន សហគមន៍ និងក្នុងការអប់រំតាមផ្ទះនៅតាមខេត្ត-ក្រុងទាំងអស់ទូទាំងប្រទេស ។

២-គ្រូមត្តេយ្យសិក្សាគ្រប់ប្រភេទត្រូវចេះប្រើសៀវភៅនេះដោយមានការច្នៃប្រឌិតបន្ថែមឱ្យស្របទៅតាមប្រធានបទប្រចាំខែ ឬតាមសភាពការណ៍ជាក់ស្ដែងនៅមូលដ្ឋានរបស់ខ្លួន ជាពិសេសត្រូវមានការនិពន្ធជាកំណាព្យខ្លីៗបន្ថែមសម្រាប់កុមារ ។

៣-មន្ត្រីទទួលបន្ទុកការងារអប់រំកុមារតូចគ្រប់លំដាប់ថ្នាក់ត្រូវយកចិត្តទុកដាក់ធ្វើយ៉ាងណាឱ្យគ្រូមត្តេយ្យសិក្សាគ្រប់កំរិតបានយល់ច្បាស់អំពីវិធីវិសាស្ត្របង្រៀនកំណាព្យ ដើម្បីធ្វើយ៉ាងណាឱ្យកុមារមានការអភិវឌ្ឍលើផ្នែកទាំងប្រាំជាពិសេសផ្នែកភាសានិយាយឱ្យបានទូលំទូលាយ និងមានការត្រៀមបានល្អសម្រាប់ចូលទៅសិក្សានៅសាលាបឋមសិក្សប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ ។

ក្រសួងអប់រំ យុវជន និង កីឡាសង្ឃឹមថាអ្នកគ្រប់គ្រងការងារអប់រំកុមារតូច និងគ្រូមត្តេយ្យសិក្សាទាំងអស់ នឹងខិតខំយកចិត្តទុកដាក់អនុវត្តសេចក្ដីណែនាំនេះឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរ ។

ភ្នំពេញ ថ្ងៃទី ០១ ខែ សីហា ឆ្នាំ២០០៧

ឧ.ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

រដ្ឋលេខាធិការ

អ៊ឹម_សិទ្ធី

ចម្លងជូន

-អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ

-អគ្គនាយកដ្ឋានអប់រំ

-អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និង កីឡាដែលពាក់ព័ន្ធ

"ដើម្បីមុខការ"

-គ្រប់មន្ទីរអប់រំ យុវជន និង កីឡាខេត្ត-ក្រុង

"ដើម្បីអនុវត្ត"

-កាលប្បវត្តិ-ឯកសារនា.អកត

## គណៈកម្មការត្រួតពិនិត្យ

- ឯកឧត្តម **ជ័យ ចាប** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា
- លោក **អ៊ុំ អេង** អគ្គនាយករងនៃអគ្គនាយកដ្ឋានអប់រំ
- លោកស្រី **សៀង សុវណ្ណនា** ប្រធាននាយកដ្ឋានអប់រំកុមារតូច
- លោកស្រី **យឹម ចាន់ស្រី** អនុប្រធាននាយកដ្ឋានអប់រំកុមារតូច

### ក្រុមបច្ចេកទេស

-លោកស្រី ផ្លុង មុនីកុសល

-លោកស្រី យស ឱអរុណ

-លោកស្រី អ៊ុម សុផានី

-លោក ឆន ឈាង

### ការិយាល័យ

-លោក ឈួន ប៊ុនឈឿន

-កញ្ញា អ៊ុក សុផាន់ណារី

-លោកស្រី ចាន់ សារឿន

# មាតិកា


| ល.រ | ខ្លឹមសារ | ទំព័រ |
|---|---|---|
| ១ | អារម្ភកថា | ១ |
| ២ | ចំណេះដឹងសម្រាប់គ្រូមត្តេយ្យសិក្សា | ២ |
| ៣ | I. បំណែងចែកសម័យកាលបង្កើតវិធីសាស្រ្តតែងនិពន្ធកំណាព្យខ្មែរ : | ២ |
| ៤ | II. កំណាព្យជាអ្វី ? | ៣ |
| ៥ | កម្រងអត្ថបទកំណាព្យ | ១៣ |
| ៦ | ◆ កំរិតទាបៈ | ១៥ |
| ៧ | ◆ កំរិតមធ្យម | ១៨ |
| ៨ | ◆ កំរិតខ្ពស់ | ២២ |
| ៩ | ◆ កំណាព្យដកស្រង់ ក្នុងឯកសារគរុកោសល្យបរិស្ថាន | ២៨ |

# អារម្ភកថា

ក្នុងដំណាក់កាលអាយុ ៦ឆ្នាំដំបូងនៃជីវិត កុមារបានកសាងមូលដ្ឋានគ្រឹះនៃបុគ្គលិកលក្ខណៈរបស់ខ្លួន ហើយក៏ជាដំណាក់កាលកំណត់ឥរិយាបថរបស់កុមារពេលក្លាយជាមនុស្សពេញវ័យ ។

វ័យមត្តេយ្យសិក្សា គឺជាវ័យមួយដែលកុមារឈានទៅទទួលបានបន្តិចម្តងៗ នូវសមត្ថភាពក្នុងការធ្វើការសម្របសម្រួលការសហការជាមួយកុមារដទៃទៀត_ហើយក៏ជាវ័យមួយដែលកុមារចាប់ផ្តើមយល់បន្តិចម្តងៗ អំពីភាសា (ពាក្យសំដី) របស់អ្នកដែលនៅជុំវិញខ្លួនគេ។ ពេលនេះហើយដែលកុមារក្លាយទៅជាមនុស្សមានសមត្ថភាពអាចនិយាយពីអ្វីៗដែលខ្លួនបានសង្កេតឃើញ និងមាននៅក្នុងចិត្ត អាចនិយាយបញ្ជាក់បានពីទំនាក់ទំនងជាមួយមនុស្សធំ តាមរយៈការពិនិត្យសង្កេត ស្តាប់ ត្រាប់តាម ។ល។

ដើម្បីឆ្លើយតបទៅនឹងការលូតលាស់ឥតឈប់ឈររបស់កុមារ មនុស្សធំត្រូវយកចិត្តទុកដាក់ណែនាំកុមារឱ្យចេះពង្រឹងរាល់ចំណេះដឹងដែលខ្លួនបានទទួលរួចហើយ ឱ្យកុមារចេះរំលែក និងធ្វើឱ្យចំណេះដឹងទាំងនោះកាន់តែទូលំទូលាយថែមទៀត តាមរយៈការផ្តល់ឱ្យកុមារនូវឱកាសដ៏សមស្រប ដើម្បីអនុវត្តជាក់ស្តែងរាល់បំណិនដែលខ្លួនមាននោះ។ ជាមួយគ្នានេះផងដែរ ការសិក្សាកំណាព្យនៅមត្តេយ្យសិក្សា មិនមែនសិក្សាស៊ីជម្រៅទៅលើវិធីសាស្ត្រ តែងនិពន្ធទូលំទូលាយ និងអត្ថន័យជ្រៅជ្រះ សម្បូរបែបនោះទេ គឺគ្រាន់តែជាការជួយសម្រួលក្នុងការនាំកុមារឱ្យចេះសូត្រកំណាព្យ ពិសេសទម្លាប់ឱ្យកុមារចេះស្តាប់ ចងចាំបាននូវកំណាព្យ ឬពាក្យចួនរបស់ខ្មែរ។ម្យ៉ាងទៀត ខ្លឹមសារសំខាន់ៗរបស់កំណាព្យនៅមត្តេយ្យសិក្សាអាចមិនត្រឹមតែចំណែកលើកទឹកចិត្តកុមារឱ្យចេះស្រឡាញ់គ្នា មានទម្លាប់ល្អ មានអនាម័យ មានសីលធម៌ និងសុជីវ-ធម៌ល្អប៉ុណ្ណោះទេ ថែមទាំងស្រឡាញ់នូវវប្បធម៌ អក្សរសាស្ត្រ អក្សរសិល្ប៍ខ្មែរទៀតផង។

ដើម្បីឆ្លើយតបទៅនឹងវត្ថុបំណងខាងលើ និងដើម្បីឱ្យគ្រូសាលាមត្តេយ្យសិក្សារដ្ឋ រោងចក្រសហគ្រាស ឯកជន និង សហគមន៍ មានឯកសារដើម្បីធ្វើជាទុនសម្រាប់យកទៅបង្រៀនប្រកបដោយប្រសិទ្ធភាព ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំចងក្រង សៀវភៅកំណាព្យមត្តេយ្យសិក្សានេះឡើង ដោយលើកយកតែចំណុចសំខាន់ៗ មកបង្ហាញជូនតែប៉ុណ្ណោះ។

ឯកសារនេះប្រាកដជានៅមានកង្វះចន្លោះខ្លះៗ ចៀសមិនផុត។ យើងខ្ញុំរង់ចាំទទួលនូវការរិះគន់ ស្ថាបនាពីគ្រប់មជ្ឈដ្ឋាន។

គណៈកម្មការរៀបរៀង និងនិពន្ធ

## ចំណេះដឹងសម្រាប់គ្រូមត្តេយ្យសិក្សា

## កំណាព្យ

### I. បំណែងចែកសម័យកាលបង្កើតវិធីសាស្ត្រតែងនិពន្ធកំណាព្យខ្មែរ :

កំណាព្យខ្មែរត្រូវបានបែងចែកជា៤សម័យកាលដូចតទៅ :

១. **សម័យកាលមុនអង្គរ** : កវីខ្មែរយើងបានបង្កើតវិធីតែងនិពន្ធកំណាព្យខ្មែរជាច្រើន ប៉ុន្តែវិធីតែងទាំងនោះត្រូវវិនាសបាត់បង់ទៅវិញ ។ សព្វថ្ងៃ យើងសង្កេតឃើញនៅសេសសល់របៀបតែងតែ២បទទេ ហើយទាំង២បទនេះក៏គេមិនសូវយកមកតែង និពន្ធទៀតផង ។ របៀបតែងទាំង ២បទដែលនៅសេសសល់នោះគឺ :

- **បទពាក្យ៤** : កើតក្នុងដំណាក់កាលនគរភ្នំ ឬ ហ្វូណន ។
- **បទបឋ្យាវត្ត** : កើតក្នុងដំណាក់កាលចេនឡា ។

២. **សម័យអង្គរ** : នៅសម័យកាលនោះ កវីខ្មែរបានបង្កើតវិធីសាស្ត្រសម្រាប់តែងកំណាព្យចំនួន៥បទ ប៉ុន្តែពុំទាន់មានឈ្មោះត្រឹមត្រូវទេ ។ គេបានសង្កេតឃើញបទទាំង៥នោះមានលំនាំតែងនិពន្ធប្រហាក់ប្រហែលទៅនឹង:

- **បទកាកគតិ**
- **បទព្រហ្មគីតិ**
- **បទបន្ទោលកាក**
- **បទពំនោល**
- **បទភុជង្គលីលា**

៣. **សម័យកាលកណ្តាល** : តាមការសិក្សាស្រាវជ្រាវប្រវត្តិសាស្ត្រ អក្សរសាស្ត្រ ក៏ដូចជាសង្គមសាស្ត្រ សម័យកាលកណ្តាលនេះបានក្តោបយកដំណាក់កាលពីរគឺ ដំណាក់កាលឧដុង្គ និងដំណាក់កាលលង្វែក។ អ្នកសិក្សាស្រាវជ្រាវបានសង្កេតឃើញថា សម័យកាលកណ្តាលនេះជាសម័យកាលដែលបានដាក់ឈ្មោះបទទាំង៥ នាសម័យកាលអង្គរឱ្យមានឈ្មោះត្រឹមត្រូវថា:

- **បទកាកគតិ**
- **បទព្រហ្មគីតិ**
- **បទបន្ទោលកាក**
- **បទពំនោល**
- **បទភុជង្គលីលា**

តាមការសិក្សាស្រាវជ្រាវបានឱ្យយើងដឹងថា សម័យកាលកណ្តាល ជាសម័យកាលដែលប្រើប្រាស់ ឬអនុវត្តយ៉ាងខ្លាំងក្លាខ្ជាប់ខ្ជួន និងយ៉ាងផ្ចិតផ្ចង់នូវវិធីសាស្ត្រតែងនិពន្ធទាំង៧បទនៃសម័យកាលមុនអង្គរ និងសម័យកាលអង្គរ។ លើសពីនេះ ទៀតកវីខ្មែរយើងបានបង្កើតវិធីសាស្ត្រតែងនិពន្ធកំណាព្យមួយបទទៀតគឺបទពាក្យ៦។ វិធីសាស្ត្រតែង និពន្ធកំណាព្យទាំង៨បទខាងលើនេះ គេហៅថា **បទបុរាណ** ។

៤. **សម័យកាលចតុមុខ** : ដោយយល់ថាបទបុរាណទាំង៨បទខាងលើ ជាបទដែលលំបាកក្នុងការតែងនិពន្ធ កវីខ្មែរយើងក៏បានបង្កើតនូវវិធីសាស្ត្រងាយៗ ក្នុងការតែងនិពន្ធចំនួន៥បទទៀតគឺ :

- បទពាក្យ ៧ - បទពាក្យ ៨
- បទពាក្យ ៩ - បទពាក្យ ១០
- បទពាក្យ ១១

បទទាំង ៥ខាងក្រោយនេះ គេឱ្យឈ្មោះថាបទ**សម័យទំនើប** ។

## II. កំណាព្យជាអ្វី ?

១. **និយមន័យ** :កំណាព្យជាសិល្បៈអក្សរបទដែលមានចំណាប់ចួនត្រឹមត្រូវតាមក្បួនខ្នាតប្រកបដោយសូរសំឡេងពីរោះរណ្តំណែងណង ដែលបង្កើតបរិយាកាសប្លែកៗនៅក្នុងបេះដូងរបស់អ្នកអាន និងអ្នកស្តាប់។ កំណាព្យដែលពិរោះមិនត្រឹមតែចេះនិពន្ធឱ្យចាប់ចុងចួនរណ្តំនោះទេ ថែមទាំងគួបផ្សំដោយមនោសញ្ចេតនាពុះពោររបស់កវីទៀតផង។

២. **កំណាព្យសម្រាប់មត្តេយ្យសិក្សាមានពីរប្រភេទគឺ** :

- កំណាព្យសម្រាប់អប់រំកុមារឱ្យមានសីលធម៌ល្អ មានអនាម័យ មានចំណេះដឹង និង ស្រឡាញ់សោភ័ណ។
- កំណាព្យដែលជ្រើសរើសក្នុងអក្សរបទនានា មកអានឱ្យកុមារស្តាប់ ដើម្បីទម្លាប់ឱ្យកុមារចេះស្តាប់ពាក្យចួនភាសាខ្មែរ ស្រឡាញ់ព្រលឹងអក្សរសិល្ប៍ខ្មែរ។

៣. **ធាតុរបស់កំណាព្យ :**

ធាតុរបស់កំណាព្យមាន៣គឺ:

- រង្វាស់កាព្យ
- ចំណាប់ចួន
- ចង្វាក់

**ក/រង្វាស់កាព្យ :** ជាចំនួនព្យាង្គ (ព្យ) ក្នុងឃ្លា (ឃ) និងចំនួនក្នុងល្បះ (ល) ។

ឧទាហរណ៍ :

+ **<u>បទបុរាណ</u>**:

**- បទពាក្យ ៤ :** ១ល = ៤ឃ
- ១ឃ = ៤ព្យ

**- បទបឋ្យាវត្ត :** ១ល = ៤ឃ
- ១ឃ = ៨ព្យ

**- បទកាកគតិ :** ១ល = ៧ឃ
- ១ឃ = ៤ព្យ

**- បទព្រហ្មគីតិ :** ១ល = ៤ឃ
- ឃ១ = ៥ព្យ

- យ២ = ៦ព្យ
- យ៣ = ៥ព្យ
- យ៤ = ៦ព្យ

- បទភុជង្គលីលា : ១ល = ៣យ
  - យ១ = ៦ព្យ
  - យ២ = ៤ព្យ
  - យ៣ = ៤ព្យ
- បទពំនោល : ១ល = ៣យ
  - យ១ = ៦ព្យ
  - យ២ = ៤ព្យ
  - យ៣ = ៦ព្យ
- បទបន្ទោលកាក : ១ល = ៤យ
  - យ១ = ៤ព្យ
  - យ២ = ៦ព្យ
  - យ៣ = ៤ព្យ
  - យ៤ = ៦ព្យ
- បទពាក្យ ៦ : ១ល= ៤យ
  - ១យ = ៦ព្យ

+<u>បទទំនើបៈ</u>

- បទពាក្យ ៧ : ១ល = ៤យ
  - ១យ = ៧ព្យ
- បទពាក្យ ៨ : ១ល = ៤យ
  - ១យ = ៨ព្យ
- បទពាក្យ ៩ : ១ល = ៤យ
  - ១យ = ៩ព្យ
- បទពាក្យ ១០ : ១ល = ៤យ
  - ១យ = ១០ព្យ
- បទពាក្យ ១១ : ១ល = ៤យ
  - ១យ = ១១ព្យ

**កំណត់សម្គាល់:** កុំច្រឡំមួយពាក្យ ទៅនឹងមួយព្យាង្គឱ្យសោះ ។ មួយព្យាង្គ គឺមួយសំឡេង ឬមួយម៉ាត់ហើយ ពុំទាន់មានន័យ ។ ឯមួយពាក្យវិញ អាចមានច្រើនព្យាង្គ ហើយមានន័យគ្រប់គ្រាន់ ។

ឧទាហរណ៍ : + សណ្តែក (២ព្យ) + កន្ទេះឡង់ (៣ព្យ)

+ កន្ទុំរុយ (៣ព្យ) + អំពិលអំពែក (៤ព្យ) ។

**ខ/ចំណាប់ចួន :** គឺជាសូរសំឡេងដែលដូចគ្នា ។ ចំណាប់ចួនដែលល្អ គឺជាចំណាប់ចួនដែលអនុវត្តតាមសូរ [អ] [អិ] ពុំនោះសោត គឺជាចំណាប់ចួនរលឿ ( សំឡេងស្រដៀងគ្នា ) ។

**ឧទាហរណ៍ :** "ពិត" ចួននឹង "គិត"

"ស្នេហា" ចួននឹង "មេត្តា"

"ពិសី" ចួននឹង "ស្រី"

"ពិសី" ចួននឹង "ទេវី" ⟶ ចំណាប់ចួនរលឿ មិនគោរពតាមសូរ [អ] [អិ]

**កំណត់សំគាល់ :** កុំច្រឡំពាក្យ "ចួន" និង "ពាក្យដូចគ្នា" :

- "មិត្ត" មិនមែនជួននឹង "មិត្ត" ទេ តែជាពាក្យដូចគ្នា ឬ ពាក្យដដែល។ ឬ ពាក្យច្រំដែល ។

*សរុបសេចក្តីទៅដើម្បីឱ្យចួនបានល្អលុះត្រាតែ :*

- តួព្យញ្ជនៈខុសគ្នា (បើមួយ "ក" មួយទៀត "ខ")
- ស្រៈដូចគ្នា (បើមួយ "ា" មួយទៀត "ា" ដែរ)

**បញ្ជាក់ :** កំណាព្យខ្មែរ មានចំណាប់ចួន៣យ៉ាងគឺ :

+ ចំណាប់ចួនក្នុងឃ្លាតែមួយ

+ ចំណាប់ចួនឆ្លងឃ្លា

+ ចំណាប់ចួនឆ្លងល្បះ

**គ/ចង្វាក់ :** ជាការលើកដាក់ បន្ទឹងបន្ធូរ សង្កត់ បន្ថែរ ឬបង្អូស សំឡេងលើព្យាង្គណាមួយនៃឃ្លាណាមួយ ។ គឺការលើកដាក់សំឡេងនេះហើយ ដែលធ្វើឱ្យកំណាព្យមានលក្ខណៈជាតន្ត្រី ។ ចង្វាក់ប្រែប្រួលទៅតាមប្រភេទបទនីមួយៗ ។

**ឧទាហរណ៍ :**

- **បទកាកគតិ :** ទម្លាក់សម្លេងលើព្យាង្គទី២ រៀងរាល់ឃ្លា
- **បទព្រហ្មគីតិ :** ទម្លាក់សម្លេងលើព្យាង្គទី២ នៃឃ្លាទី១-៣
  ទម្លាក់សម្លេងលើព្យាង្គទី៣ នៃឃ្លាទី២-៤
- **បទបន្ទោលកាក :** ទម្លាក់សម្លេងលើព្យាង្គទី២ នៃឃ្លាទី១-៣
  ទម្លាក់សម្លេងលើព្យាង្គទី៤ នៃឃ្លាទី២-៤
- **បទពាក្យ ៧ :** ទម្លាក់សម្លេងលើព្យាង្គទី២ និងទី៤រៀងរាល់ឃ្លា

- បទពាក្យ ៨ : ទម្លាក់សម្លេងលើព្យាង្គទី៣ និងព្យាង្គទី៥
- បទពាក្យ ៩ : ទម្លាក់សម្លេងលើព្យាង្គទី៣ និងព្យាង្គទី៦

## ៣. លក្ខណៈពិសេសរបស់កំណាព្យ :

*ខ្លីប៉ុន្តែខ្លឹម : លើកលែងតែកំណាព្យរឿង កំណាព្យដែលល្អ មិនមែនសំដៅលើអត្ថបទវែងអន្លាយនោះទេ។ អត្ថបទកំណាព្យខ្លះវែង ច្រើនឃ្លា ច្រើនល្បះ ច្រើនទំព័រ ប៉ុន្តែខ្លឹមសារមានតិចតួចស្តួចស្តើងពេក។ កំណាព្យដែលល្អគឺ មានលក្ខណៈខ្លី ប៉ុន្តែពោរពេញដោយខ្លឹមសារ។ កវីមានទេពកោសល្យ ក្នុងការប្រមូលផ្តុំគំនិតធំៗ សំខាន់ៗ (វិធីកំណុំ និងកំហាប់ ។

* ភាសាកាព្យ : ជាភាសាពិសេសដែលគេប្រើប្រាស់ ក្នុងការតែងនិពន្ធកំណាព្យ។ ភាសានេះមានលក្ខណៈ ទន់ភ្លន់ មានទឹកដម ពីរោះរណ្តំណែងណង និងមានរូបារម្មណ៏រស់រវើកកវីថ្លឹងថ្លែង និងប្រយ័ត្នប្រយែងក្នុងការសិរិតសំរាំងចំរាញ់ពាក្យពេចន៏ ឃ្លាឃ្លោង ។

លក្ខណៈពិសេសទាំងពីរខាងលើនេះ អាចបង្កើតបានគ្រប់ទិដ្ឋភាព បរិយាកាសក្នុងបេះដូងអ្នកអាន និងអ្នកស្តាប់។

## ៤. មេកាព្យ ឬ កាព្យមូលដ្ឋាន :

☞ បទពាក្យ៤ :

- វង្វាស់កាព្យ : ១ល = ៤ឃ
  - ១ឃ = ៤ព្យ
- ចំណាប់ចួន :

ល១
១ ២ ៣ ៤ ១ ២ ៣ ៤
១ ២ ៣ ៤ ១ ២ ៣ ៤ ។

ល២
១ ២ ៣ ៤ ១ ២ ៣ ៤
១ ២ ៣ ៤ ១ ២ ៣ ៤ ។

ល១
ឱម្លប់ដូងអើយ ដែលបងអង្គុយ
បងអត់ងងុយ ចាំស្រីរវៃ ។

ល២
ចិត្តបងតែងចាំ ភ្នែកបងរំពៃ
ចាំស្រីរវៃ ចុះមកជួបបង ។

☞ បទបឋ្យាវត្ត :

- វង្វាស់កាព្យ : ១ល = ៤ឃ
  - ១ឃ = ៨ព្យ

- ចំណាប់ចួន :

ល១ { ១ ២ ៣ ៤ ៥ ៦ ៧ ៨ ១ ២ ៣ ៤ ៥ ៦ ៧ ៨
១ ២ ៣ ៤ ៥ ៦ ៧ ៨ ១ ២ ៣ ៤ ៥ ៦ ៧ ៨ ។

ល២ { ១ ២ ៣ ៤ ៥ ៦ ៧ ៨ ១ ២ ៣ ៤ ៥ ៦ ៧ ៨
១ ២ ៣ ៤ ៥ ៦ ៧ ៨ ១ ២ ៣ ៤ ៥ ៦ ៧ ៨ ។

ល១ { ព្រលឹមដូចយប់ព្រលប់ដូចថ្ងៃ ប្រឡូងថ្មីដៃប្រល័យពូជសាសន៍
ក្រឡៃក្រឡាប់ផ្កាប់ផ្ងារក្រឡះ សាកសពដេរដាសក្រាស់ក្រាលលោកកីយ៍ ។

ល២ { ភ្នំឆ្អឹងស្ទឹងឈាមដាមជិតដក់ដី ពាលអសុរីបិសាចភ្នែកស្រស់
ជីវិតពិតជាជួរចត់ក្រៀមក្រោះ រលាយបាត់អស់សិទ្ធិសេរីភាព ។

☞ បទពំនោល :

- រង្វាស់កាព្យ : ១ល = ៣ឃ

• ឃ១ = ៦ព្យ
• ឃ២ = ៤ព្យ
• ឃ៣ = ៦ព្យ

- ចំណាប់ចួន :

ល១ ១ ២ ៣ ៤ ៥ ៦ ១ ២ ៣ ៤ ១ ២ ៣ ៤ ៥ ៦ ។

ល២ ១ ២ ៣ ៤ ៥ ៦ ១ ២ ៣ ៤ ១ ២ ៣ ៤ ៥ ៦ ។

ល១ បងអើយទោសអ្វីធ្ងន់ម្ល៉េះ រល្ងយរលេះ ស្រាំប្រេះលលាដ៏ក្សិណក្ស័យ ។

ល២ នៅសល់តែឆ្អឹងប្រុសថ្លៃ ពួកពាលចង្រៃ ប្រល័យបងបណ្តូលចិត្ត ។

☞ បទភុជង្គលីលា :

- រង្វាស់កាព្យ : ១ល = ៣ឃ

• ឃ១ = ៦ព្យ
• ឃ២ = ៤ព្យ
• ឃ៣ = ៤ព្យ

- ចំណាប់ចួន :

ល១ ១ ២ ៣ ៤ ៥ ៦ ១ ២ ៣ ៤ ១ ២ ៣ ៤ ។

ល២ ១ ២ ៣ ៤ ៥ ៦ ១ ២ ៣ ៤ ១ ២ ៣ ៤ ។

ល១ លលកទំជ្រកដើមជ្រៃ សន្ទឹងសន្ទៃ មមៃរកគូ ។

ល២ ប្រាសព្រាត់កំសត់ចត់ជូរ ខន្តីតស៊ូ ទោះយូរយ៉ាងណា ។

☞ បទបន្ទោលកាក :

- រង្វាស់កាព្យ : ១ល = ៤ឃ

- ឃ១ = ៤ព្យ
- ឃ២ = ៦ព្យ
- ឃ៣ = ៤ព្យ
- ឃ៤ = ៦ព្យ

- ចំណាប់ចួន : មាន ២ទម្រង់

<u>ទម្រង់ទី១</u> :

ល១
១ ២ ៣ ៤ ១ ២ ៣ ៤ ៥ ៦
១ ២ ៣ ៤ ១ ២ ៣ ៤ ៥ ៦ ។

ល២
១ ២ ៣ ៤ ១ ២ ៣ ៤ ៥ ៦
១ ២ ៣ ៤ ១ ២ ៣ ៤ ៥ ៦ ។

ល១
ខ្លួនខ្ញុំធ្ងន់ណាស់ លោកម្ចាស់អាណិតមេត្តា
ដល់ខ្ញុំផងណា ធ្ងន់ត្រាខ្ញុំទ្រាំលែងបាន ។

ល២
នែឯងជាគ្រឹះ ចាក់ឫសទ្រាំតាមកម្មប្រាណ
ទ្រអញឱ្យបាន ក្សែមក្សាន្តសង្ខារឈ្មោះល្បី ។

<u>ទម្រង់ទី២</u> :

ល១
១ ២ ៣ ៤ ១ ២ ៣ ៤ ៥ ៦
១ ២ ៣ ៤ ១ ២ ៣ ៤ ៥ ៦ ។

ល២
១ ២ ៣ ៤ ១ ២ ៣ ៤ ៥ ៦
១ ២ ៣ ៤ ១ ២ ៣ ៤ ៥ ៦ ។

ល១
ថ្លែងដោយទំនង ដំណើរដើមទងចចក
ក្នុងពេលទឹកស្រក ចចកដើរខកចំណី ។

ល២
ប្រាំពីរថ្ងៃគត់ ចចកដើររត់សព្វដី
លុះបានជួបត្រី ចចកក៏ឆីតាមឃ្លាន ។

☞ បទកាកគតិ :

- រង្វាស់កាព្យ : ១ល =៧ឃ
  - ១ឃ =៤ព្យ

- ចំណាប់ចួន :

ល១
១ ២ ៣ ៤ ១ ២ ៣ ៤ ១ ២ ៣ ៤
១ ២ ៣ ៤ ១ ២ ៣ ៤ ១ ២ ៣ ៤
១ ២ ៣ ៤ ។

ល២
១ ២ ៣ ៤ ១ ២ ៣ ៤ ១ ២ ៣ ៤
១ ២ ៣ ៤ ១ ២ ៣ ៤ ១ ២ ៣ ៤
១ ២ ៣ ៤ ។

ល១
បើស្អាតអ៊ីចឹង បើស្រស់ម្ល៉ឹងៗ គានតឹងអំពល់
ចិត្តចលាចល ច្របល់វិលវល់ មន្តស្នេហ៍និមល
ពារជល់បងហើយ ។

លព
យល់សប្តិយល់សួង ធ្វើម្នាស់បេះដូង គេងគងក្បៀកកើយ
ស្រមោលនួនល្អង លងបងឥតស្បើយ វង្វេងកោះត្រើយ
ឆ្លងឆ្លើយម្នាក់ឯង ។

☞ បទព្រហ្មគីតិ :

- រង្វាស់កាព្យ : ១ល = ៤ឃ
  - ឃ១ = ៥ព្យ
  - ឃ២ = ៦ព្យ
  - ឃ៣ = ៥ព្យ
  - ឃ៤ = ៦ព្យ

- ចំណាប់ចួន :

លវ
១ ២ ៣ ៤ ៥ ១ ២ ៣ ៤ ៥ ៦
១ ២ ៣ ៤ ៥ ១ ២ ៣ ៤ ៥ ៦ ។

លព
១ ២ ៣ ៤ ៥ ១ ២ ៣ ៤ ៥ ៦
១ ២ ៣ ៤ ៥ ១ ២ ៣ ៤ ៥ ៦ ។

ល១ { ឱកូនសម្លាញ់ពុក កូនផុតទុក្ខរស់សុខា
ដោយគុណមករា សាងអាត្មាឱ្យបានល្អ ។

ល២ { កុំយកពៀរសងពាល នាំរោលរាលជាប់បន្ត
សាងជាតិឱ្យបវរ អង្គរថ្មដីស្ពឹមស្មៃ ។

☞ បទពាក្យ៦ :

- រង្វាស់កាព្យ : ១ល=៤ឃ

• ១ឃ =៦ព្យ

- ចំណាប់ចួន :

ល១ { ១ ២ ៣ ៤ ៥ ៦ ១ ២ ៣ ៤ ៥ ៦
១ ២ ៣ ៤ ៥ ៦ ១ ២ ៣ ៤ ៥ ៦ ។

ល២ { ១ ២ ៣ ៤ ៥ ៦ ១ ២ ៣ ៤ ៥ ៦
១ ២ ៣ ៤ ៥ ៦ ១ ២ ៣ ៤ ៥ ៦ ។

ល១ { មួយកាលខ្ញុំនៅលង្កា នគររាពណ៍ណាយង់ឃ្នង
ស្ដេចឱ្យហនុមានហោះផ្សង ទៅសួរដឹងសព្វសេចក្ដី ។

ល២ { ទោះបីខ្ញុំកាចខ្ញុំជា ជ្រាបក្នុងចិន្ដាហើយនៃ
លុះតែស្រេចសង្គ្រាមជ័យ ស្ដេចឱ្យខ្ញុំលុយអគ្គី ។

☞ បទពាក្យ៧ :

- រង្វាស់កាព្យ : ១ល=៤ឃ

• ១ឃ =៧ព្យ

- ចំណាប់ចួន :

ល១ { ១ ២ ៣ ៤ ៥ ៦ ៧ ១ ២ ៣ ៤ ៥ ៦ ៧
១ ២ ៣ ៤ ៥ ៦ ៧ ១ ២ ៣ ៤ ៥ ៦ ៧ ។

ល២ { ១ ២ ៣ ៤ ៥ ៦ ៧ ១ ២ ៣ ៤ ៥ ៦ ៧
១ ២ ៣ ៤ ៥ ៦ ៧ ១ ២ ៣ ៤ ៥ ៦ ៧ ។

ល១ { ទឹកហូរសន្ទឹកសន្ធាប់ព្រៃ សន្ទឹងសន្ធៃវែងអន្លាយ
សន្ធំសណ្ឋិតចិត្តនិងកាយ សម្បូរសប្បាយសម្បត្តិខ្មែរ ។

ល២ { សម្បុកស្តុកស្តម្ភស្តាយសែនស្តាយ អាប់អន្តរាយហិនហូរហែ
អសោចខ្លោចឈ្មៀមក្រៀមក្តើរម៉ែ ទន្លេបឹងបែរប្រែកំព្រា ។

☞ **បទពាក្យ៨ :**

- **រង្វាស់កាព្យ :** ១ល = ៤ឃ
    - ១ឃ = ៨ព្យ
- **ចំណាប់ចួន :** មាន ២ទម្រង់សំខាន់ៗ

**ទម្រង់ទី១:**

ល១
១ ២ ៣ ៤ ៥ ៦ ៧ ៨ ១ ២ ៣ ៤ ៥ ៦ ៧ ៨
១ ២ ៣ ៤ ៥ ៦ ៧ ៨ ១ ២ ៣ ៤ ៥ ៦ ៧ ៨ ។

ល២
១ ២ ៣ ៤ ៥ ៦ ៧ ៨ ១ ២ ៣ ៤ ៥ ៦ ៧ ៨
១ ២ ៣ ៤ ៥ ៦ ៧ ៨ ១ ២ ៣ ៤ ៥ ៦ ៧ ៨ ។

ល១
មកដោយសេចក្ដីគិតមានអាល័យ ដែលអាឡោះនឹកថ្លៃសោកសែនសល់
ហើយសែនណែនទ្រូងខ្ញុំទ្រាំទុក្ខទល់ ទ្រាំទុក្ខទៀបដាច់ខ្យល់ខ្ចាត់ពីកាយ ។

ល២
ពីកើតមករៀមមិនដែលទុក្ខដូច្នឹង ទុក្ខដូច្នេះសមនឹងទ្រូងប្រេះខ្ចាយ
ទ្រូងបែកខ្ចាត់បាត់ជន្មចេញពីកាយ ទុក្ខផ្សាពុំរសាយសាន្តទុក្ខា ។

**ទម្រង់ទី២:**

ល១
១ ២ ៣ ៤ ៥ ៦ ៧ ៨ ១ ២ ៣ ៤ ៥ ៦ ៧ ៨
១ ២ ៣ ៤ ៥ ៦ ៧ ៨ ១ ២ ៣ ៤ ៥ ៦ ៧ ៨ ។

ល២
១ ២ ៣ ៤ ៥ ៦ ៧ ៨ ១ ២ ៣ ៤ ៥ ៦ ៧ ៨
១ ២ ៣ ៤ ៥ ៦ ៧ ៨ ១ ២ ៣ ៤ ៥ ៦ ៧ ៨ ។

ល១
ប្រាសាទកំពូលប្រាំខ្ពស់ត្រដែត ល្អហួសហេតុលើសលប់ភពលោកា
គ្មានជនជាតិណាមួយក្នុងទ្វីបា ស្ថាបនាអោយបានដូចអង្គរ ។

ល២
យើងជាខ្មែរគ្រប់រូបមានអំនួត លើកស្ទួយអួតបង្ហាញមិនភូតភរ
ដល់ជនជាតិនានាគ្រប់នគរ ឮល្បីខ្ចរពាសពេញទាំងទ្វីបា ។

☞ **បទពាក្យ៩ :**

- **រង្វាស់កាព្យ :** ១ល = ៤ឃ
    - ១ឃ = ៩ព្យ
- **ចំណាប់ចួន :**

ល១
១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩
១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ។

ល២
១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩
១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ។

ល១ { ផ្ការក្នុង១ទ្រូងក្ដីកក្ដាក់ញាក់រណ្ដំ រន្ទះខំចំកោងស្រែកហែករាត្រី
ភ្លៀងដូចខឹងប្រឹងស្រោចស្រពសព្វផែនដី ស្មៅខ្សៀវខ្ចីខ្លីលិចបាត់ស្ងាត់លែងយល់ ។

ល២ { ភ្លៀងស្រងល់ខ្យល់បន្តវ៉ៃវ៉ារ១ ! ខ្ញីបខ្សៀវខ្សារការបក់បោកខោកវិលវល់
កួចក្រោមលើឈើលែងឈររលើងគល់ ប្រឹងទប់ទល់ជល់នឹងខ្យល់សល់សោកា ។

*ដើម្បីឱ្យស្រឡះងាយអាន គេនិយមសរសេរបែបនេះ :*

| | | | |
|---|---|---|---|
| ល១ | ផ្ការក្នុង១ | ទ្រូងក្ដីកក្ដាក់ | ញាក់រណ្ដំ |
| | រន្ទះខំ | ចំកោងស្រែក | ហែករាត្រី |
| | ភ្លៀងដូចខឹង | ប្រឹងស្រោចស្រព | សព្វផែនដី |
| | ស្មៅខ្សៀវខ្ចី | ខ្លីលិចបាត់ | ស្ងាត់លែងយល់ ។ |
| ល២ | ភ្លៀងស្រងល់ | ខ្យល់បន្ត | វ៉ៃវ៉ារ១ ! |
| | ខ្ញីបខ្សៀវខ្សារ | ការបក់បោក | ខោកវិលវល់ |
| | កួចក្រោមលើ | ឈើលែងឈរ | រលើងគល់ |
| | ប្រឹងទប់ទល់ | ជល់នឹងខ្យល់ | សល់សោកា ។ |

☞ បទពាក្យ១០ :

- វង្វាស់កាព្យ : ១ល=៤ឃ
  - ១ឃ =១០ព្យ
- ចំណាប់ចួន :

ល១ { ១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១០ ១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១០
១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១០ ១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១០ ។

ល២ { ១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១០ ១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១០
១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១០ ១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១០ ។

☞ បទពាក្យ១១ :

- វង្វាស់កាព្យ : ១ល = ៤ឃ
  - ១ឃ =១១ព្យ
- ចំណាប់ចួន :

ល១ { ១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១០ ១១ ១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១០ ១១
១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១០ ១១ ១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១០ ១១ ។

ល២ { ១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១០ ១១ ១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១០ ១១
១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១០ ១១ ១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១០ ១១ ។

# កម្រងអត្ថបទកំណាព្យ

| ថ្នាក់ | ខ្លឹមសារកំណាព្យ | ឈ្មោះបទ |
|---|---|---|
| កម្រិតទាប | ១. ត្រូវចេះគួរសមមុនពេលចេញទៅផ្ទះ | បទកាកគតិ |
| (អាយុ៣ឆ្នាំ) | ២. ត្រូវចេះជម្រាបសួរពុកម៉ែ យាយ តា | - |
| | ៣. អ្នកគ្រូមត្តេយ្យ | - |
| | ៤. កុមារមត្តេយ្យ | - |
| | ៥. យើងថែទាំល្បែងលេង | - |
| | ៦. កុមារថ្មី | - |
| | ៧. យើងស្រឡាញ់អ្នកគ្រូ | - |
| | ៨. មិត្តថា សត្វអ្វី? | - |
| | ៩. សម្លៀកបំពាក់ | - |
| | ១០. ដៃប្អូនទាំងពីរ | បទភុជង្គលីលា |
| កម្រិតមធ្យម | ១. យើងតម្រង់ជួរ | បទកាកគតិ |
| (អាយុ៤ឆ្នាំ) | ២. ខ្ញុំស្រឡាញ់មាតុភូមិ | - |
| | ៣. មិត្តចំណាំ បានអ្វីខ្លះ? | - |
| | ៤. ធំឡើងខ្ញុំធ្វើយោធា | - |
| | ៥. ខ្ញុំអាយុ៤ឆ្នាំ | - |
| | ៦. ត្រូវហូបទឹកឆ្អិន | - |
| | ៧. ល្បែងលេងនានា | - |
| | ៨. យើងសាមគ្គីគ្នា | - |
| | ៩. ចេះថែទាំសម្លៀកបំពាក់ | បទព្រហ្មគីតិ |
| | ១០. ជើងប្អូន | - |
| | ១១. សំអាតកាយ | - |
| កម្រិតខ្ពស់ | ១. ពេលដើរតាមផ្លូវ | បទកាកគតិ |
| (អាយុ៥ឆ្នាំ) | ២. យើងរៀនគ្រប់មុខវិជ្ជា | - |
| | ៣. យើងទៅសាលា | - |
| | ៤. មិត្តស្គាល់អ្វីខ្លះ? | - |
| | ៥. ត្រូវធ្វើពលកម្ម និងចិញ្ចឹមសត្វ | - |

| | | |
|---|---|---|
| | ៦. អ្នកគ្រូយើង | - |
| | ៧. មិត្តចំណាំបានអ្វីខ្លះ? | - |
| | ៨. សាលា និងផ្ទះ | - |
| | ៩. ពាក្យបណ្ដៅ ដើមឈូក | - |
| | ១០. ពាក្យបណ្ដៅសត្វដីរី | - |
| | ១១. ត្រូវធ្វើពលកម្ម | - |
| | ១២. ដើរក្រោមកំដៅថ្ងៃ | បទព្រហ្មគីតិ |
| | ១៣. ហាត់ប្រាណដើម្បីសុខភាព | បទកាកគតិ |
| | ១៤. ខែទាំង១២ | បទព្រហ្មគីតិ |
| | ១៥. ឆ្នាំខ្មែរទាំង១២ | បទកាកគតិ |
| <u>កំណាព្យ</u> | ១. សួនសាធារណៈ | - |
| <u>ក្នុងគរុកោសល្យបរិស្ថាន</u> | ២. សិប្បកម្ម តុ ទូ | - |
| | ៣. ដើមត្នោត | - |
| | ៤. ពិធីបុណ្យអុំទូក | - |
| | ៥. សំណង់ពូយើង | - |
| | ៦. ចំការចេកតា | - |
| | ៧. ដុំអិដ្ឋល្អឯក | - |
| | ៨. ម៉ាញ៉ៅ | - |
| | ៩. ផលប្រយោជន៍អិដ្ឋពណិ | - |
| | ១០. ផលប្រយោជន៍ក្រមា | - |
| | ១១. លូ អណ្ដូង | - |
| | ១២. រដូវចម្រូត | - |
| | ១៣. ម៉ាស៊ីនអារឈើ | - |
| | ១៤. យើងថែទាំដំណាំ | - |
| | ១៥. យើងដាំឫស្សី | |

# កម្រងចម្រៀងកុមារ

**ត្រូវចេះគួរសមមុនពេលចេញទៅផ្ទះ** (បទកាកគតិ)

មុនពេលទៅផ្ទះ លើកដៃសំពះ
ជម្រាបលាគ្រូ ហើយតម្រង់ជួរ
មួយគូៗ កុំឱ្យយឺតយូរ
ខាតពេលវេលា ។

**ត្រូវចេះជម្រាបសួរពុកម៉ែ យាយតា** (បទកាកគតិ)

ពេលទៅដល់ផ្ទះ យើងត្រូវសំពះ
ជម្រាបពុកម៉ែ លោកយាយ លោកតា
ពូមីងផងដែរ តាមទំម្លាប់ខ្មែរ
យើងពីបុរាណ ។

**អ្នកគ្រូមត្តេយ្យ** (បទកាកគតិ)

អ្នកគ្រូមត្តេយ្យ ជាម្ដាយទីពីរ
របស់យើងខ្ញុំ គាត់ថែរក្សា
ព្រមទាំងណែនាំ ឱ្យពួកយើងខ្ញុំ
រៀនផងលេងផង ។

**កុមារមត្តេយ្យ** (បទកាកគតិ)

យើងខ្ញុំកុមារ មត្តេយ្យសាលា
ត្រូវស្ដាប់ពាក្យពេចន៍ អ្នកគ្រូប្រដៅ
ត្រាប់តាមជានិច្ច មិនត្រូវរេះគេច
ឱ្យអ្នកគ្រូព្រួយ ។

## យើងថែទាំល្បែងលេង (បទកាកគតិ)

ប្រដាប់ប្រដា មានល្បែងគ្រៀបគ្រា
យើងលេងរាល់ថ្ងៃ ត្រូវចែកមិត្តភក្តិ
ហើយចេះគិតថ្លៃ ថែទាំសំចៃ
កុំឱ្យបាក់បែក ។

## កុមារថ្មី (បទកាកគតិ)

កម្ពុជាថ្មី កុមារមេត្តាយ្យ
ស្រឡាញ់គ្រប់គ្នា ប្តេជ្ញាខំរៀន
ហើយ និងការពារ ដែនកម្ពុជា
ឱ្យបានគង់វង្ស ។

## យើងស្រឡាញ់អ្នកគ្រូ (បទកាកគតិ)

ខ្ញុំស្រឡាញ់គ្រូ គាត់ចេះគិតគូរ
ឱ្យយើងបានថ្កើង ស្រឡាញ់ដូចបង
ដូចពុកម៉ែយើង មកមិត្តកុំឆ្មើង
ធ្វើតាមអ្នកគ្រូ ។

## មិត្តថាសត្វអ្វី? (បទកាកគតិ)

មិត្តអើយសត្វអ្វី រស់នៅលើដី
មានរោមមានស្លាប ម្រាមជើងជាប់គ្នា
ស្រែកពួកាប១ ដំណើរដូចក្រាប
ចំពុះវាវែង ។
មិត្តអើយសត្វនោះ ខ្ញុំឆ្លើយមិនខុស

ប្រាប់ទៅមិត្តឯង គឺជាសត្វទា
ស្លាបពីរកវែង ក្បាលមូលត្រមែង
ភ្នែកពីរតូចៗ ។

## សម្លៀកបំពាក់ (បទកាកគតិ)

សម្លៀកបំពាក់ បោកហាលទុកដាក់
រក្សាឱ្យល្អ ស្លៀកពាក់ត្រឹមត្រូវ
ជិតពោះទ្រូង ក សុខភាពបវរ
មាំទាំមាំមួន ។

## ដៃប្អូនទាំងពីរ (បទភុជង្គលីលា)

ដៃប្អូនដុសធ្មេញឱ្យ ស ឱ្យបានស្អាតល្អ
ចាំង ស ដូចភ្លុក ។
ដៃប្អូនសិតសក់វែកមុខ សក់វែងចងទុក
សិតស្លូតទៅក្រោយ ។



# កម្រិតមធ្យម

**យើងតម្រង់ជួរ** (បទកាកគតិ)

សូរជួងម៉ឹងៗ រត់មកពួកយើង
ឈរទន្ទឹមគ្នា រៀបបានជាជួរ
កុំនៅវេរា ត្រង់ល្អម្ទីម្ទា
យើងដើរចូលថ្នាក់ ។

**ខ្ញុំស្រឡាញ់មាតុភូមិ** (បទកាកគតិ)

ឱកម្ពុជា យើងខ្ញុំគ្រប់គ្នា
ស្រឡាញ់អ្នកណាស់ វាលភ្នំទន្លេ
ព្រៃក្បាស្តើងក្រាស់ សម្បូរឥតខ្វះ
ពេញពសុធា ។
ខ្ញុំប្តេជ្ញាថា ធំឡើងកាលណា
ចូលធ្វើយោធា ឆន្ទៈមោះមុត
កសាងការពារ ដែនកម្ពុជា
ឱ្យបានគង់វង្ស ។

**មិត្តចំណាំបានអ្វីខ្លះ?** (បទកាកគតិ)

មិត្តអើយជួយចាំ ខំជួយចំណាំ
មានផ្លែអ្វីខ្លះ មានពណ៌ខុសគ្នា
លឿងក្រហមចាស់ ផ្លែខ្លះសាច់ក្រាស់
ទឹកដមឈ្ងុយឆ្ងាញ់ ។

## **ធំឡើងខ្ញុំធ្វើយោធា** (បទកាកគតិ)

អាយុបួនឆ្នាំ ខ្ញុំរៀនឱ្យចាំ
តាមអ្នកគ្រូថា រៀនគ្រប់វិជ្ជា
មត្តេយ្យសាលា ធំឡើងកាលណា
ខ្ញុំធ្វើយោធា ។
លះបង់ទាំងអស់ ការពារដោយស្មោះ
ចិត្តខ្ញុំធានា រក្សាឱ្យបាន
សុខសាន្តគ្រប់គ្រា ឱ្យកម្ពុជា
មានសន្តិភាព ។

## **ខ្ញុំអាយុបួនឆ្នាំ** (បទកាកគតិ)

អាយុបួនឆ្នាំ ខ្ញុំរៀនចេះចាំ
លេខ ១-២-៣ ចេះទាំងគូររូប
កូនមាន់កូនត្រី ចេះទាំងស្រដី
និទានរឿងផង ។
នៅផ្ទះខ្ញុំជួយ ធ្វើការជាមួយ
ពុកម៉ែ និងបង ស្រោចទឹកបន្លែ
ចាប់ដង្កូវផង ធំឡើងខ្ញុំប៉ង
ធ្វើកសិករ ។

## **ត្រូវហូបទឹកឆ្អិន** (បទកាកគតិ)

យើងជាកុមារ ត្រូវតែចាំថា
គួរហូបទឹកឆ្អិន បើឃើញទឹកឆៅ
ត្រូវបង្អង់សិន ចាំហូបទឹកឆ្អិន
ទើបគ្មានមេរោគ ។

## ល្បែងលេងនានា (បទកាកគតិ)

ល្បែងតុក្កតា រូបមាន់ឆ្កែឆ្មា
គោសេះដំរី កូនក្រមុំជ័រ
ទន្សាយទាត្រី លេងទាំងប្រុសស្រី
សប្បាយអស្ចារ្យ ។
ឡានរទេះភ្លើង ល្បែងឡុកឡាក់យើង
ថែទាំរក្សា កុំឱ្យបាក់បែក
រហែកឡើយណា ទើបបានឈ្មោះថា
ជាកុមារល្អ ។

## យើងសាមគ្គីគ្នា (បទកាកគតិ)

កុមារមត្តេយ្យ ទាំងប្រុសទាំងស្រី
សាមគ្គីសាមគ្គា ពេលរៀនពេលឈប់
គ្រប់ពេលវេលា យកអាសាគ្នា
កុំខ្លាចនឿយហត់ ។
យើងជួយស្រោចផ្កា ជួយបោសសាលា
ឱ្យបានម៉ត់ចត់ យើងរៀនធ្វើការ
ឱ្យបានចេះស្ទាត់ ពេលភ័យកុំរត់
ចោលមិត្តភក្តិយើង ។

## ចេះថែទាំសម្លៀកបំពាក់ (បទព្រហ្មគីតិ)

ខោអាវត្រូវថែទាំ តាមលំនាំលំអោនស្រាប់
កុំវាយឥតសណ្ដាប់ មិនគួរគាប់នឹងភ្នែកញាតិ ។
ជាកូនមានបទល្អ មិនដែលក្រឥតមារយាទ
ទុកដាក់ហើយចេះឆ្លៀត ជួយការទៀតជំនួសម្ដាយ ។

**ជើងប្អូន** (បទព្រហ្មគីតិ)

ជើងតូចរបស់ប្អូន សស្រលូនគួរទម្លាប់
ថៃពាក់ថែមទ្រនាប់ ឱ្យបានជាប់ជាលំអ ។
ដើររត់មិនភ័យព្រួយ មានស្បែកជួយជើងជាល្អ
មិនពងមុត ឬដរ កមក្រមរ មិនបៀតបៀន ។

**សំអាតកាយ** (បទព្រហ្មគីតិ)

ពេលក្រោកពីព្រលឹម មុខញញឹមរីករស់ស្រាយ
ម្ទីម្នាសំអាតកាយ មិនទ្បើយណាយរៀបទុកដាក់ ។
មុងភួយកន្ទេលខ្នើយ រៀបឱ្យហើយដោយស្មោះស្ម័គ្រ
កុំផ្ទុកលើម្ដាយម្នាក់ ត្រូវចេះភ្ជាក់ជួយគ្រប់គ្រា ។



# កម្រិតខ្ពស់

**ពេលដើរតាមផ្លូវ** (បទកាកគតិ)

ពេលដើរតាមផ្លូវ កូនអើយកូនត្រូវ
តែប្រកាន់ស្ដាំ ដើរអែបខាងៗ
គ្រប់យ៉ាងកូនចាំ កុំភ្លេចបណ្ដាំ
ដើរស្ដាំជានិច្ច ។

ពេលឆ្លងកាត់ផ្លូវ កូនអើយកូនត្រូវ
ប្រយ័ត្នមិនភ្លេច ត្រូវមើលមុខក្រោយ
សញ្ញាភ្លើងរំលេច ប្រុងខ្លួនជានិច្ច
ទើបគេចផុតគ្រោះ ។

**យើងរៀនគ្រប់មុខវិជ្ជា** (បទកាកគតិ)

មត្តេយ្យកុមារ ខិតខំសិក្សា
រៀនលេងរៀនគូរ យើងរៀនគិតលេខ
រៀនមើលគំនូរ ព្រមទាំងស្ដាប់គ្រូ
និទានរឿងផង ។

យើងរាំយើងច្រៀង រៀនស្ដាប់សូរសៀង
កំណាព្យបងៗ យើងដើរទស្សនា
ហើយសង្កេតផង ហាត់ប្រាណបំណង
បានខ្លួនត្រង់ល្អ ។

**យើងទៅសាលា** (បទកាកគតិ)

មកពួកមិត្តអើយ កុំនៅកន្តើយ

យើងទៅសាលា　　　　យើងលេងយើងគួរ
យើងដើរទស្សនា　　　　កន្លែងនានា
បង្កើនចំណេះ ។
សង្កេតឱ្យច្បាស់　　　　រួចហើយគួរវាស់
តាមការចាំចេះ　　　　យើងដាំបន្លែ
បានផ្លែយើងបេះ　　　　មិត្តកុំគេចវេះ
យើងទៅសាលា ។

**មិត្តស្គាល់អ្វីខ្លះ?** (បទកាកគតិ)

មិត្តចាំបានទេ　　　　នោះឈ្មោះអ្វីគេ
ព្យួរចំពីមុខ　　　　បើមិត្តថាត្រូវ
មិត្តអស់មានសុខ　　　　ស្គាល់ចំណាំទុក
ខ្ញុំសូមសរសើរ ។

**ត្រូវធ្វើពលកម្ម និង ចិញ្ចឹមសត្វ** (បទកាកគតិ)

កុមារប្រុសស្រី　　　　ត្រូវខំឃ្មាតខ្មី
រៀនធ្វើពលកម្ម　　　　រៀនដាំបណ្ដុះ
សព្វផលដំណាំ　　　　ស្រោចទឹកប្រចាំ
ថៃកុំទំនេរ ។
យើងចិញ្ចឹមមាន់　　　　បានស៊ុតគ្រប់គ្រាន់
មិនខ្វះញ៉ាំទេ　　　　យើងចិញ្ចឹមទា
ក៏បានពងដែរ　　　　ដោយយើងចេះថែ
ឱ្យចំណីសត្វ ។

## **អ្នកគ្រូយើង** (បទកាកគតិ)

អ្នកគ្រូយើងអើយ នៅជិតបង្កើយ
ក្បែរកិតកុមារ លួងលោមថ្នាក់ថ្នម
អស់ពីចិន្តា ប្រៀបបុត្រស្នេហា
រក្សាលើកស្ទួយ ។
ពួកយើងសង្ឃឹម អ្នកគ្រូញញឹម
រង់ចាំតែជួយ ដោះស្រាយមុខក្រោយ
មិនឱ្យមានព្រួយ យើងចិត្តតែមួយ
ស្រឡាញ់អ្នកគ្រូ ។

## **មិត្តចំណាំបានអ្វីខ្លះ?** (បទកាកគតិ)

មិត្តអើយជួយចាំ ខំជួយចំណាំ
មានផ្លែអ្វីខ្លះ មានពណ៌ខុសគ្នា
លឿងក្រហមចាស់ ផ្លែខ្លះសាច់ក្រាស់
ទឹកដមឈ្ងុយឆ្ងាញ់ ។

## **សាលា និង ផ្ទះ** (បទកាកគតិ)

នៅផ្ទះម៉ាក់ប៉ា ស្រឡាញ់រក្សា
ថែទាំកក់ក្ដៅ ពេលមកសាលា
អ្នកគ្រូប្រដៅ មិនឱ្យល្ងង់ខ្លៅ
មោះមុតក្លាហាន ។
យើងសើចក្អាកក្អាយ សាលាសប្បាយ
ច្រៀងរាំកំសាន្ត រៀនគួរស្ដាប់រឿង
ចងចាំគ្រប់ប្រាណ ស្រឡាញ់រាប់អាន
ប្រៀបបានបងប្អូន ។

## ពាក្យបណ្ដៅដើមឈូក (បទកាកគតិ)

ដើមវាប៉ុនទៀន កាលណាវាល្មៀន
ស្លឹកធំប៉ុនថាស បើមិត្តគិតឃើញ
សូមឆ្លើយឱ្យច្បាស់ ពាក្យប្រដៅចាស់
ដើមនេះដើមអ្វី?

មិត្តអើយដើមនោះ ខ្ញុំទាយមិនខុស
ស្លឹកបៃតងខ្ចី គឺជាដើមឈូក
ដើមប៉ុនមេដៃ ផ្កាក្រអូបក្រៃ
សាច់វាឆ្ងាញ់ណាស់ ។

## ពាក្យបណ្ដៅសត្វដំរី (បទកាកគតិ)

មិត្តអើយចាំរក គិតហើយឆ្លើយមក
ប្រាប់ខ្ញុំវិញណា មានសត្វមួយនោះ
មាឌធំអស្ចារ្យ លើសសត្វនានា
តែភ្នែកតូចណាស់ ។

មិត្តអើយខ្ញុំដឹង ឈ្មោះសត្វមួយហ្នឹង
ខ្ញុំស្គាល់យ៉ាងច្បាស់ ពណ៌ខ្លួនក្របី
ធំខ្ពស់ស្រឡះ ប្រមោយវវ៉ែស
គឺសត្វដំរី ។

## ត្រូវធ្វើពលកម្ម (បទកាកគតិ)

ពលកម្មកុមារ យើងត្រូវឧស្សាហ៍
ប្រឹងប្រែងរាល់ថ្ងៃ យើងធ្វើពីក្មេង
ចាស់ទៅធ្លាប់ដៃ ចេះគិតចេះច្នៃ
កសាងសេដ្ឋកិច្ច ។

ពេលធ្វើពលកម្ម យើងត្រូវចំណាំ
យើងមិនត្រូវភ្លេច យកចបកាំបិត
បង្ហើមកស្រេច កាប់គាស់កំទេច
វល្លិស្មៅក្នុងធ្លា ។

**ដើរក្រោមកំដៅថ្ងៃ** (បទព្រហ្មគីតិ)

សត្វចាបញីឈ្មោលច្រៀង មានគូក្បៀងលើព្រឹក្សា
ទោះបីក្តៅយ៉ាងណា ក៏បក្សាមិនខ្វល់ខ្វាយ ។
ឯយើងត្រូវការពារ ទើបធានាសុខសប្បាយ
ពាក់មួកទៅជិតឆ្ងាយ សុខទាំងកាយសប្បាយចិត្ត ។

**ហាត់ប្រាណដើម្បីសុខភាព** (បទកាកគតិ)

អរុណរះហើយ ឱប្អូនៗអើយ
នាំគ្នាក្រោកឡើង ហាត់ពត់កាយា
លើកដៃ លើកជើង ងើបមុខខ្ពស់ឡើង
ស្រូបយកខ្យល់ល្អ ។
កុំខ្មាសកុំអៀន ត្រូវតែប្រឹងប្រៀន
សុខភាពបវរ នាំកាយចម្រើន
រឹងមាំដូចថ្ម ជំងឺអន្តរ
ប្រាជ្ញាភ្លឺស្វាង ។

**ខែទាំង ១២** (បទព្រហ្មគីតិ)

ទីមួយខែមករា ពីរសោតណាខែកុម្ភៈ
ទីបីមីនាជាក់ បួនលើកដាក់ខែមេសា ។
ឧសភាខែទីប្រាំ ប្រាំមួយចាំមិថុនា

ប្រាំពីរខែកក្កដា ខែសីហាទីប្រាំបី ។
ប្រាំបួនខែកញ្ញា ដប់តុលាលោកស្រដី
ដប់មួយវិច្ឆិកាប្រិមប្រិយ៍ ដប់ពីរថ្មីត្រូវខែធ្នូ ។

**ឆ្នាំខ្មែរទាំង ១២** (បទកាកគតិ)

ខ្ញុំចេះទាំងអស់ ជូត ឆ្លូវ ខាល ថោះ
ចង់ចាំហូរហែ រោង ម្សាញ់ មមី
មមែ ឆ្នាំខ្មែរ វក រកា ដែរ
ច កុរ ក្រោយគេ ។



# កំណាព្យដកស្រង់
# ក្នុងឯកសារគរុកោសល្យបរិស្ថាន

**សួនសាធារណៈ** (បទកាកគតិ)

ទុំះទ៏ សួនច្បារ មានស្មៅមានផ្កា
ពណ៌ក្រហមលឿង សិរមាន់ទំហូ
ចន្ទស្បៃរឿង រីករះរុងរឿង
ចំកណ្ដាលសួន ។

**សិប្បកម្ម តុ ទូ** (បទកាកគតិ)

កៅអីតុទូ ស្អាដៃពូៗ
នៅរោងសិប្បកម្ម ម៉ែទិញដាក់ផ្ទះ
ជូតជាប្រចាំ ប្រើប្រាស់យូរឆ្នាំ
ស្អាតភ្លឺរលោង ។

**ដើមត្នោត** (បទកាកគតិ)

កូនមើលដើមត្នោត ដូនតាដាំដោត
នៅលើដីកេរ្តិ៍ ពីដើមរៀងមក
ល្អឯកឥតទ្វេ ស្លឹកសោតយើងដេរ
ប្រក់លំនៅស្ថាន ។
ត្នោតតាដុះហៃ នៅលើភ្លឺស្រែ
រុងរឿងច្រើនថ្កាន មានផ្លែមានផ្កា
ស្លហូបក៏បាន សង់ផ្ទះចំណាន
យើងបានសុខា ។
ពូកាន់ពូគាប ផ្កាល្អដោយឃ្នាប

ទឹកផ្អែមណាស់ណា រំងាស់ជាសុរ
ឈើយឆ្ងាញ់អស្ចារ្យ ម៉ែអាចប្រើការ
ធ្វើនំគ្រប់មុខ ។

## ពិធីបុណ្យអុំទូក (បទកាកគតិ)

មិត្តអើយឃើញទេ នៅក្នុងទន្លេ
មានទូកច្រើនក្រៃ ខ្លះអុំខ្លះចែវ
បង្ហាញថ្វីដៃ គំរប់បីថ្ងៃ
ប្រពៃណីជាតិ ។

ទំនៀមទំលាប់ ខែដប់មួយជាប់
អារម្មណ៍ផៅញាតិ ធ្វើបុណ្យអុំទូក
ប្រជាព្រោងព្រាត គ្រប់គ្នាខ្មីឃ្មាត
ចូលរួមសប្បាយ ។

## សំណង់ពូយើង (បទកាកគតិ)

ពូៗកម្មករ មានចិត្តស្មោះសរ
ប្រឹងឥតបង្អង់ ខ្លះចូកខ្លះឃ្សូរ
ទាញខ្សែតំរង់ ដើម្បីសាងសង់
អគារថ្មីយើង ។

មើលពូកម្មករ រីករាយបវរ
ញាប់ដៃញាប់ជើង អគារតូចធំ
លេចត្រដែតឡើង ស្នាដៃពូយើង
បានល្អអស្ចារ្យ ។

## ចំការចេកតា (បទកាកគតិ)

ថ្ងៃមួយនោះណា ខ្ញុំទៅផ្ទះតា
ឃើញតាដាំចេក តាដាំជាជួរ
ត្រង់ល្អអនេក ខ្ញុំសប្បាយពេក
ជួយដាំចេកតា ។

## គ្រឿងល្អឯក (បទកាកគតិ)

ឱ!ពូកម្មករ ទឹកចិត្តស្មោះសរ
ធ្វើការឥតអាក់ កាប់ជ្រុំជ្រួយដី
បែកញើសសស្រាក់ មិនមានថ្នាំងថ្នាក់
ជាន់ដីយ៉ាងសឿង ។
រួចហើយពូយក ដីអិដ្ឋនោះមក
បញ្ចូលពុម្ពគ្បឿង រួចដុតចំអិន
ពណ៌ក្រហមឿង ផ្សំបានគ្រប់គ្រឿង
ប្រក់ដំបូលផ្ទះ ។

## ម៉ាញ៉ៅ (បទកាកគតិ)

មិត្តអើយនុះន៍ អ្វីនៅបញ្ឃ្បរ
ក្បែរ១រាងកាយ មានចុចមានមូល
ខ្សែរដោតបន្ទាយ សូរស័ព្ទលាន់ឆ្ងាយ
ពីរោះម្ល៉េះទេ ។
រូបរាងបួនជ្រុង ទ្រវែងមានខ្ទង់
យើងខ៊ិះរេ រៀនបើករៀនដាក់
កាសែតម៉ាញ៉ៅ ពេលយើងទំនេរ
រាំលេងសប្បាយ ។

## ផលប្រយោជន៍អិដ្ឋពណ៌ (បទកាកគតិ)

ហៃពួកមិត្តយើង ប្រញាប់ឆាប់ឡើង
រួតរះម្ទីម្ទា មើលផ្ទាក់រៀនយើង
ពួខ្លះលាបទ្វារ ពួខ្លះស្រោយលា
បត់ឡាំងអិដ្ឋពណិ ។
រលើបរលោង រលីងដូចត្បូង
ចែងចាំងបវរ ក្រហមលាយលឿង
ខៀវបៃតងស ក្រាលផ្ទះភ្លឺល្អ
យើងសែនបេតី ។
អិដ្ឋពណិមានផល យើងមិនខ្វាយខ្វល់
ជាន់ប្រលាក់ដី យើងនាំគ្នាជួយ
ទាំងប្រុសទាំងស្រី បោសជូតឃ្មាតខ្មី
ថែទាំជានិច្ច ។

## ផលប្រយោជន៍ក្រមា (បទកាកគតិ)

ក្រមាសំខាន់ ស្លៀកមិនប្រកាន់
ជូតក្បាលអស្ចារ្យ បង់កពេនា
ទៅវត្តហ៊ីហា ក្រមានេះណា
អ៊ំខ្ញុំគាត់ត្បាញ ។

## លូ អណ្ដូង (បទកាកគតិ)

អង្គុយឱ្យជិត យើងខំពិនិត្យ
ការលាយបាយអ ដាក់ខ្សាច់ដាក់ទឹក
ស៊ីម៉ង់ និង ថ្ម រៀបពុម្ពឱ្យឈរ
ចាក់លូអណ្ដូង ។

## រដូវចម្រូត (បទកាកគតិ)

ចម្រូតដល់ហើយ កសិករអើយ
ខិតខំធ្វើការ ច្រូតកាត់បោកបែន
ប្រមូលផល្លា ចិញ្ចឹមអាត្មា
តទៅថ្ងៃមុខ។

## ម៉ាស៊ីនអារឈើ (បទកាកគតិ)

ហ៊ុបមូលធំៗ ដឹកពីព្រៃភ្នំ
គរផ្គុំត្រៀបត្រា បញ្ចូលម្ដងមួយ
ក្រោមម៉ាស៊ីនអារ ច្រៀកដោយរណារ
ក្ដារឈើគ្រប់ធុន។

## យើងថែទាំដំណាំ (បទកាកគតិ)

មកមិត្តរាល់ព្រឹក បោចស្មៅស្រោចទឹក
សណ្ដែកកួរយើង កំពុងចេញផ្កា
របាំងពេញទ្រើង ផ្លែលេចចេញឡើង
ទាំងកួរៗ។

## យើងដាំឫស្សី (បទកាកគតិ)

ខ្ញុំដាំឫស្សី យកធ្វើអ្វីៗ
បានតាមត្រូវការ ដើមតូចដើមធំ
តាមចិត្តប្រាថ្នា យើងខំរក្សា
វាឱ្យបានល្អ។